គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០២ គ.ជ.ប. ស.ណ.ន

# សេចក្តីណែនាំ
## ស្តីពី
## ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគ ព្រមទាំងការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតមើលតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមជម្រាបជូន លោក លោកស្រីប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និងគណបក្សនយោបាយ ជ្រាបថា ដំណើរការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ និងការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត បានបញ្ចប់ជាស្ថាពរហើយ ដោយមានគណបក្សនយោបាយចំនួន ៤ (បួន) បានឈរឈ្មោះបោះឆ្នោតទាំង ៨ (ប្រាំបី) មណ្ឌលភូមិភាគ។ ដូចនេះ គ.ជ.ប សូមធ្វើការណែនាំដល់ គធ.ខប និងគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការទាំងអស់អំពីការងារមួយចំនួនដែលត្រូវអនុវត្តជាបន្ត ដូចតទៅ ៖

### ១. ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគ

- គធ.ខប ត្រូវចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការទាំងអស់នៃភូមិភាគក្នុងរាជធានី ខេត្តរបស់ខ្លួន។ គធ.ខប ត្រូវធ្វើការថតចម្លងបន្ថែមនូវបញ្ជីទាំងនេះតាមចំនួនចាំបាច់គ្រប់គ្រាន់ ដើម្បីបិទផ្សាយតាមគោលដៅ ដូចខាងក្រោម ៖
  - លេខាធិការដ្ឋាននៃ គធ.ខប ១ (មួយ) ច្បាប់
  - តាមទីប្រជុំជនធំៗមួយចំនួន ក្នុងរាជធានី ខេត្ត។
- កាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការត្រូវធ្វើចាប់ពី**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤** ជាកំណត់។

### ២. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតមើលតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួន ២ (ពីរ) រូប ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប និងភ្នាក់ងារបម្រុង ១ (មួយ) រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗនៅតាមរាជធានី ខេត្តនៃភូមិភាគដែលខ្លួនឈរឈ្មោះបោះឆ្នោត។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយមានរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ **គឺចាប់ផ្តើមនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៤ បញ្ចប់នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤។**
- គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គធ.ខប រៀងរាល់ម៉ោងធ្វើការ **ពេលព្រឹកចាប់ពីម៉ោង ៧ : ០០ (ប្រាំពីរ) ដល់ម៉ោង ១១ : ៣០ (ដប់មួយសាមសិប) នាទី និង ពេលរសៀលចាប់ពីម៉ោង ១៤ : ០០ (ដប់បួន) ដល់ម៉ោង ១៧ : ៣០ (ដប់ប្រាំពីរសាមសិប) នាទី។**
- គធ.ខប ទាំងអស់ត្រូវស្នើសុំកិច្ចសហការ និងសម្របសម្រួលជាមួយអាជ្ញាធរដែនដី ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតពាក់ព័ន្ធនឹងការស្នើសុំចេញលិខិតបញ្ជាក់អំពីភាពមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ សម្រាប់បំពេញបែបបទដាក់ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយនៅ គធ.ខប។

**គធ.ខប** ទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះជូនដល់**អាជ្ញាធរមានសមត្ថកិច្ច គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត** សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងក្របខណ្ឌរាជធានី ខេត្តរបស់ខ្លួនឱ្យបានទូលំទូលាយ ដើម្បីត្រៀមសហការ និងចូលរួមអនុវត្តតាមភារកិច្ចរៀងៗខ្លួនស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។

គ.ជ.ប សង្ឃឹមទុកជាមុនថា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់នឹងយកចិត្តទុកដាក់សហការឱ្យបានល្អ ដើម្បីជំរុញឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: គ.ជ.ប

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០២៤

# បញ្ជីរាយនាម
## គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
## ភូមិភាគទី ១ រាជធានីភ្នំពេញ

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ្វ៊ុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០២៤

## បញ្ជីរាយនាម
### គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
### ភូមិភាគទី ២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ្វ៊ុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

ថ្ងៃ សុក្រ ៨រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០២៤

## បញ្ជីរាយនាម
## គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
## ភូមិភាគទី ៣ ខេត្តកណ្ដាល

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ៊្វុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២៤

## បញ្ជីរាយនាម

## គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ភូមិភាគទី ៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន

| | | |
|---|---|---|
| ១ | | គណបក្សប្រជាជនកម្ពុជា<br>ប្រ.ជ |
| ២ | | គណបក្ស ឆន្ទៈខ្មែរ<br>គ.ឆ.ខ |
| ៣ | | គណបក្សហ៊្វុនស៊ិនប៉ិច<br>រ.រ.ជ.ក.ឯ.អ.ស.ស |
| ៤ | | គណបក្ស កម្លាំងជាតិ<br>គ.ក.ជ |

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ: គ.ជ.ប**

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០២៤

# បញ្ជីរាយនាម
## គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
## ភូមិភាគទី ៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ៊្វុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ: គ.ជ.ប**

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៤

## បញ្ជីរាយនាម
## គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
## ភូមិភាគទី ៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ្វ៊ុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

ថ្ងៃ សុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៤

## បញ្ជីរាយនាម
### គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
### ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ៊្វុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

ថ្ងៃ ព្រហ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២៤

## បញ្ជីរាយនាម
### គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
### ភូមិភាគទី ៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី

| | | |
|---|---|---|
| ១ | | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |
| ២ | | **គណបក្ស ឆន្ទៈខ្មែរ**<br>**គ.ឆ.ខ** |
| ៣ | | **គណបក្សហ៊្វុនស៊ិនប៉ិច**<br>**រ.រ.ជ.ក.ឯ.អ.ស.ស** |
| ៤ | | **គណបក្ស កម្លាំងជាតិ**<br>**គ.ក.ជ** |